# រឿងរបស់ ចច រិកហ្វដ

នៅឆ្នាំ ១៩៦៩ ចច រិកហ្វដ ដែលជាយុវមជ្ឈិមវ័យម្នាក់រស់នៅក្នុងរដ្ឋលេសេសស្ទើរ ប្រទេសអង់គ្លេស បានជួបនឹងពួកអ្នកផ្សព្វផ្សាយសាសនាមកពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ដំបូងឡើយ ចច បានបដិសេធនឹងសារលិខិតរបស់ពួកគេ ប៉ុន្តែនៅទីបំផុត គាត់បានចាប់ផ្ដើមជួបនឹងពួកអ្នកផ្សព្វផ្សាយសាសនា ។ បន្ទាប់ពីការស៊ើបអង្កេតយ៉ាងដិតដល់អស់រយៈពេលបីខែមក នៅព្រឹកមួយ ចច បានក្រោកឡើងពីដំណេកជាមួយនឹងការជឿជាក់ថា សាសនាចក្រនេះគឺជាសាសនាចក្រពិត ។

ចចមានចិត្តចង់ចែកចាយទីបន្ទាល់ដែលរកឃើញថ្មីរបស់គាត់ជាមួយនឹងពួកដែលមានវ័យចាស់ជាងខ្លួន ។ មុនពេលគាត់អាចធ្វើដូច្នេះបាន ពួកគេបានជូនដំណឹងដល់គាត់ថា គាត់នឹងគ្មានសិទ្ធិទទួលបានបព្វជិតភាពក្នុងនាមសមាជិកសាសនាចក្រទេ ដោយសារមរតកពូជសាសន៍ចម្រុះរបស់គាត់ដែលរួមបញ្ចូលពូជពង្សនៃជនជាតិអាហ្វ្រិកស្បែកខ្មៅ ។

ថ្ងៃមួយ ចចកំពុងនិយាយនឹងមិត្តស្និទ្ធស្នាលម្នាក់អំពីបទពិសោធន៍របស់គាត់ជាមួយនឹងពួកអ្នកផ្សព្វផ្សាយសាសនា ហើយបានចាប់ផ្ដើមបង្រៀនមិត្តគាត់អំពីព្យាការីយ៉ូសែប ស៊្មីធ ។ គាត់បានចាំថា « ពេលខ្ញុំបានប្រាប់ពីដំណើររឿងនោះ ខ្ញុំមានចិត្តរំភើបយ៉ាងខ្លាំង ហើយបានធូរស្រាល » ។

បទពិសោធន៍នោះបានបញ្ជាក់ជាថ្មីដល់ទីបន្ទាល់របស់ចច ប៉ុន្តែកង្វល់របស់គាត់ពីបម្រាមបព្វជិតភាពនៅតែមានដដែល ។ ពេលគាត់អធិស្ឋានទូលសូមការយល់ដឹងបន្ថែមទៀត សារលិខិតនេះបានកើតឡើងចំពោះគាត់ ៖ « អ្នកពុំចាំបាច់យល់អ្វីគ្រប់យ៉ាងអំពីដំណឹងល្អរបស់យើងឡើយ ពីមុនអ្នកប្ដេជ្ញាចិត្តខ្លួនចំពោះដំណឹងល្អនោះ ។ ហេតុអ្វីអ្នកមិនបង្ហាញសេចក្ដីជំនឿរបស់អ្នកដោយទទួលយកអ្វីដែលអ្នកបានឮ ហើយទុកអ្វីដែលនៅសេសសល់នៅក្នុងព្រះហស្តរបស់យើង ? »

ដោយបានទទួលការលួងលោមចិត្តមកពីសារលិខិតនោះ ចចបានឆ្លើយតបប្រកបដោយការអធិស្ឋានថា « បពិត្រ ព្រះអម្ចាស់ ទូលបង្គំនឹងធ្វើតាម ។ ទូលបង្គំនឹងទទួលយកដំណឹងល្អដោយសេចក្ដីជំនឿ ។ ហើយសូមអរព្រះគុណទ្រង់យ៉ាងខ្លាំង » ។ ពីរខែក្រោយមក ចចបានជ្រមុជទឹក ហើយបានក្លាយជាសមាជិកដ៏ស្មោះត្រង់ម្នាក់ក្នុងសាសនាចក្រ ។

ក្នុងឆ្នាំ ១៩៧៥ បីឆ្នាំមុនវិវរណៈអំពីបព្វជិតភាព នោះចចបានបង្ហាញជំនឿរបស់គាត់លើព្រះដ៏សុចរិត ដោយសរសេរថា គាត់ទទួលយកបម្រាមនោះ « ដោយសេចក្ដីជំនឿ ដោយគ្មានលក្ខខណ្ឌឡើយ » ។ គាត់បានបន្ថែមថា ៖ « ខ្ញុំមានអំណរគុណដែលបព្វជិតភាពរបស់ព្រះអម្ចាស់មានជាថ្មីម្ដងទៀតលើផែនដីនេះ រួមទាំងរាល់ពរជ័យ សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់វាផងដែរ ។ វាពុំមែនជាបញ្ហាចំពោះខ្ញុំនោះទេដែលថានរណាខ្លះមានវា ឬគ្មានវានោះ ប៉ុន្តែសំខាន់គឺរបៀបដែលវាត្រូវបានប្រើប្រាស់វិញទេតើ » ។

ក្នុងឆ្នាំ ១៩៧៨ ចចបានរៀនអំពីវិវរណៈដែលពង្រីកបព្វជិតភាពដល់បុរសស័ក្ដិសមទាំងអស់ ( សូមមើល សេចក្ដីប្រកាសជាផ្លូវការទី ២ ) ។

« ពេលចចបានត្រឡប់មកផ្ទះវិញ គាត់ និងជូន [ ភរិយារបស់គាត់ ] បានជជែកគ្នាពេញមួយយប់អំពីអត្ថន័យនៃដំណឹងនេះចំពោះគ្រួសាររបស់ពួកគេ ។ ការផ្លាស់ប្ដូរនេះគឺអស្ចារ្យណាស់ ។ នៅព្រឹកបន្ទាប់ ចច រិកហ្វដ ត្រូវបានតែងតាំងជាសង្ឃនៅក្នុងបព្វជិតភាពអើរ៉ុន ។ ពីរខែក្រោយមក គាត់ត្រូវបានតែងតាំងជាពួកចិតសិបនាក់ ហើយធ្វើជាសមាជិករៀមច្បងក្នុងកូរ៉ុមចិតសិបនាក់ប្រចាំស្តេក ។ ហើយពីរខែបន្ទាប់ពីនោះ ចច និង ជូន រិកហ្វដ បានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ទីក្រុងឡុងដ៏ ប្រទេសអង់គ្លេស រួមជាមួយនឹងកូនប្អូននាក់របស់ពួកគេ » ( « I Will Take It in Faith » ) ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ឆ្នាំ ២០២៣ by Intellectual Reserve, Inc. All rights reserved.
PD60013873_258_115-teacher_handout-1